ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# សារលិខិតរំលែកទុក្ខ

**ជូនចំពោះ**

**ឯកឧត្តម សូ ម៉ារ៉ា រដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ព្រមទាំងក្រុមគ្រួសារ**

**ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ជាទីគោរពរាប់អានដ៏ជ្រាលជ្រៅ!**

ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ពិតជាមានក្តីក្តុកក្តួលរន្ធត់ចិត្តឥតឧបមាដោយបានទទួលដំណឹងថា **មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ជាម លាត** ដែលត្រូវជាម្តាយបង្កើតជាទីគោរពស្រឡាញ់បំផុតរបស់ **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី** បានទទួលមរណភាព កាលពីថ្ងៃអាទិត្យ ១២រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩ ត្រូវនឹងថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៥ វេលាម៉ោង ៩:២៥នាទីយប់ ក្នុងជន្មាយុ ៩០ឆ្នាំ ដោយជរាពាធ។

ក្នុងឱកាសប្រកបដោយក្តីខ្សឹកខ្សួលរំជួលចិត្តដ៏មហាក្រៀមក្រំនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវសមានទុក្ខប្រកបដោយអនិច្ចលក្ខណធម៌ដ៏ជ្រាលជ្រៅ ព្រមទាំងក្តីសង្វេគដ៏ធំធេង និងពោរពេញដោយក្តីសោកស្តាយស្រណោះអាឡោះអាល័យជាអនេកប្បការ ចំពោះការបាត់បង់ **មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ជាម លាត** ដែលជាពុទ្ធសាសនិកមួយរូប បានបូជាអស់កម្លាំងកាយចិត្ត ប្រាជ្ញាស្មារតី រួមចំណែកលើកកម្ពស់ដល់វិស័យព្រះពុទ្ធសាសនានៅកម្ពុជាយ៉ាងច្រើន ដើម្បីបម្រើផលប្រយោជន៍ជូនជាតិ មាតុភូមិ និងជាការបាត់បង់ម្តាយបង្កើតម្តាយក្មេក ជីដូន ជាទីគោរពស្រឡាញ់បំផុត ដែលកន្លងមកលោកបានខិតខំប្រឹងប្រែង តស៊ូចិញ្ចឹមបីបាច់ថែរក្សាទំនុកបម្រុងសព្វបែបយ៉ាងដល់ក្រុមគ្រួសារ ព្រមទាំងផ្តល់ឱវាទអប់រំទូន្មាន និងក្តីស្រឡាញ់ដ៏ជ្រាលជ្រៅប្រកបដោយព្រហ្មវិហារធម៌ថ្លៃថ្លាគួរជាទីគោរព និងស្រឡាញ់ស្មើជីវិតចំពោះកូន និងចៅ។

ជាថ្មីម្តងទៀត ខ្ញុំ និងភរិយា ព្រមទាំងថ្នាក់ដឹកនាំ និងមន្ត្រីរាជការ នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមលំឱនកាយឧទ្ទិសបួងសួងដល់ដួងវិញ្ញាណក្ខន្ធ **មហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៍ ជាម លាត** សូមឆាប់បានយោនយកកំណើតក្នុងសុគតិភពកុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមរដ្ឋមន្ត្រីប្រតិភូអមនាយករដ្ឋមន្ត្រី ព្រមទាំងក្រុមគ្រួសារ** ទទួលនូវការចូលរួមរំលែកទុក្ខដ៏ក្រៀមក្រំ និងការស្រឡាញ់រាប់អានយ៉ាងជ្រាលជ្រៅពីយើងខ្ញុំ។

ថ្ងៃអង្គារ ១៤រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២៥

**រដ្ឋមន្ត្រី**

**ហេង សួរ**